**អភិបូជារំលឹកលោកឪពុកគ្រឿង ម៉ូយៀប**

**ធ្វើនៅព្រះសហគមន៍ផ្លូវត្រី**

**ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២**

**"កសាងសុខសន្តិភាពតាមគំរូមរណៈសាក្សី"**

**អត្ថបទទី១៖ ទុតិយកថា ២៦,១៦-១៩**

ព្រះអម្ចាស់យល់ព្រមទទួលអ្នកជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់។ ទក ២៦,១៨

**ដំណឹងល្អ៖ ម៉ាថាយ ៥,៤៣-៤៨**

សូម្បីតែអ្នកទារពន្ធ*ក៏ចេះស្រឡាញ់គ្នាគេដែរ។ មថ ៥,៤៦

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ ដែលយើងជួបជុំគ្នាដើម្បីនឹករលឹកដល់លោកឪពុក ហ្វ្រង់ស្វ័រសាវីយ៉េ យៀប ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ផ្លូវត្រីយើងនៅឆ្នាំ១៩២៤។ មានន័យថា ព្រះសហគមន៍របស់យើងជាព្រះសហគមន៍ចាស់ហើយ ព្រះសហគមន៍របស់យើងជាព្រះសហគមន៍ដែលមានគ្រីស្តបរិស័ទពីដើម។ ដែលបានចាប់ផ្ដើមសាបព្រោះនៅលើទឹកដីរបស់យើង ដើម្បីណែនាំឱ្យជីវិតបានរីកចម្រើន ពីមួយថ្ងៃទៅមួយថ្ងៃព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចមានផ្លែដ៏ពិតប្រាកដមែន។

បងប្អូនជាទីស្រឡាញ់ យើងនៅខាងកើតនៃទន្លេមេគង្គ យើងមានបីកន្លែងពិសេស ទីមួយមានផ្លូវត្រី យើងនឹករលឹកដល់លោកឪពុកយៀប ដែលបានធ្វើការអស្ចារ្យយ៉ាងច្រើនសម្រាប់ប្រជាជនមួយចំនួន ទាំងពុទ្ធបរិស័ទ ទាំងគ្រីស្តបរិស័ទ។ ជាពិសេស នៅប្រទេសវៀតណាម ហើយនៅកន្លែងយើងក៏យើងមានផ្លែនៅក្នុងជីវិតរបស់យើងដែរ។ ទីពីរ ព្រះសហគមន៍សន្តសិលា ពោធិ៍ធំ ក៏ជាកន្លែងមួយពិសេសដែរ ជាព្រះសហគមន៍កំណើតរបស់លោកអភិបាល ឆ្មារ សាឡាស់ លោកឪពុក ឆ្មារ សាឡឹម។ ជាមរណៈសាក្សី ដែលបានសុខចិត្តលះបង់អ្វីៗទាំងអស់ នៅប្រទេសកម្ពុជាក្នុងសម័យប៉ុលពត ជីវិតរបស់ពួកគាត់ក៏បានធ្លាក់នៅក្នុងដី ដើម្បីទៅជាពូជដែលមានផ្លែយ៉ាងច្រើន ដូចយើងបានស្ដាប់នៅក្នុងគម្ពីរដំណឹងល្អអំបាញ់មិញ។ ទីបី ព្រះសហគមន៍ក្បត្រីនៃសន្តិ

ភាព អរិយក្សត្រ ជាកន្លែងព្រះនាងម៉ារីនៃទន្លេមេគង្គ ព្រះនាងម៉ារីទី១យើងរកឃើញនៅឆ្នាំ២០០៨ ព្រះនាងម៉ារីទី២យើងរកឃើញនៅឆ្នាំ២០១២។

ដូច្នេះ ពេលយើងមើលតាមផ្លូវខាងកើតទន្លេមេគង្គ ជាកន្លែងដែលព្រះអាទិត្យរះ ជាកន្លែងដែលយើងនឹករលឹកដល់ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូដែលជាពន្លឺ ព្រះយេស៊ូដែលជាព្រះអាទិត្យដើម្បីបំភ្លឺពិភពលោក ណែនាំឱ្យយើងអាចទទួលកម្លាំងយ៉ាងច្រើនដើម្បីរីកចម្រើន។ មិនមែនរីកចម្រើននៅក្នុងការរកស៊ី មិនមែនរីកចម្រើននៅក្នុងទ្រព្យសម្បត្តិ ប៉ុន្តែអ្វីដែលសំខាន់មិនមែនឱ្យយើងរកស៊ីតាមលោកិយ៍។ លោកយៀប នៅក្នុងជីវិតរបស់គាត់បានបម្រើព្រះជាម្ចាស់ បានបម្រើព្រះសហគមន៍ បានស្រឡាញ់សន្តីម៉ារី បានស្រឡាញ់សន្តយ៉ូសែប នេះជាអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់យើង។ ជាពិសេស នៅក្នុងរដូវអប់រំពិសេស យើងធ្វើដូចម្តេចដើម្បីឱ្យយើងផ្ទាល់ខ្លួនភ្ជាប់ជាមួយព្រះជាម្ចាស់ យើងធ្វើដូចម្តេចដើម្បីឱ្យយើងអាចទទួលរង្វាន់នៅស្ថានបរមសុខ។ រង្វាន់នៅស្ថានបរមសុខ មិនមែនសម្រាប់តែអ្នកមានដែលមានឋានៈ មិនមែនសម្រាប់តែអ្នកដែលមានទ្រព្យសម្បត្តិច្រើន គឺសម្រាប់មនុស្សសុចរិត។ មានន័យថា មនុស្សដែលធ្វើអំពើល្អ ដោយរស់នៅស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ យើងមានសន្តយ៉ូសែប សន្តយ៉ូហានបាទីស្ទ លោកតាអប្រាហាំ...។

ថ្ងៃនេះ យើងចូលរួមនៅក្នុងអភិបូជានេះដើម្បីបំពេញសេចក្តីសង្ឃឹមរបស់យើង តាមរយៈលោកយៀប តាមរយៈលោកឆ្មារ សាឡាស់ និងឆ្មារ សាឡឹម តាមរយៈព្រះនាងម៉ារីនៃទន្លេមេគង្គ ដើម្បីឱ្យយើងទៅជាមនុស្សសុចរិត។ មានន័យថា ជាមនុស្សម្នាក់ដែលបានខិតខំនៅក្នុងជីវិតសាមញ្ញធម្មតា រស់នៅជាមួយគ្រួសារយើង នៅក្នុងព្រះសហគមន៍យើង នៅក្នុងសង្គមយើង នៅក្នុងសេចក្តីសុខដែលយើងទទួលពីព្រះជាម្ចាស។ នៅពេលយើងនិយាយអំពីសេចក្តីសុខ យើងត្រូវតែមើលឃើញសង្គ្រាមដែលកំពុងកើតឡើងនៅទ្វីបអឺរ៉ុប យើងជាពិភពតែមួយដែលត្រូវតែព្រួយបារម្ភ។ យើងខ្លាចសង្គ្រាមរវាងអ៊ុយក្រែន និងរុស្ស៊ី ក្លាយជាសង្គ្រាមលោកលើកទី៣ សម្រាប់យើងជាគ្រីស្តបរិស័ទ ជាពេលវេលាដើម្បីអធិដ្ឋាន។ ពីម្សិលមិញ អ្នកដឹកនាំទាំង២៧ប្រទេសនៅទ្វីបអឺរ៉ុប បានប្រជុំគ្នាហើយចេញសេចក្តីសម្រេចរួមមួយ គឺជួយឧបត្ថម្ភ ១ពាន់លានដុល្លារអាមេរិក ដើម្បីទិញអាវុធសម្រាប់អ៊ុយក្រែន។

ដូច្នេះ សូមបងប្អូនអធិដ្ឋានទូលអង្វរទាំងព្រះនាងម៉ារី ទាំងសន្តយ៉ូសែប ទាំងលោកយៀប ទាំងឆ្មារសាឡាស់ ទាំងឆ្មារសាឡឹម និងសន្តសន្តីទាំងអស់នៅស្ថានបរមសុខ ដើម្បីឱ្យយើងបញ្ចប់សង្គ្រាម

បន្ទាន់ ឱ្យមនុស្សយើងចេះមើលឃើញបញ្ហាដែលកំពុងកើតឡើង។ គេថាមានប្រហែល ៥លាន នាក់ ដែលបានភៀសខ្លួនចេញពីប្រទេសអ៊ុយក្រែន ទៅប្រទេសនានា ដើម្បីគេចពីសង្គ្រាម។ ថ្ងៃនេះ ជាពេលវេលាដើម្បីស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ថែមទៀត ដើម្បីអធិដ្ឋានថែមទៀត ដើម្បីកែប្រែចិត្តគំនិតថែមទៀត។ អធិដ្ឋានសម្រាប់អ្នកដែលដឹកនាំប្រទេសទាំងអស់នៅក្នុងពិភពលោក ដើម្បីឱ្យយើងទាំងអស់គ្នាមានគោលដៅតែមួយ គឺកសាងសុខសន្តិភាព។ កសាងសុខសន្តិភាព កុំឱ្យគ្រាន់តែជាពាក្យដែលយើងនិយាយចេញពីបបូរមាត់របស់យើង ឱ្យយើងអនុវត្តយ៉ាងជាក់ស្តែង នៅក្នុងគ្រួសារយើង នៅក្នុងព្រះសហគមន៍យើង នៅក្នុងជីវិតរបស់យើង នៅក្នុងដួងចិត្តរបស់យើងផ្ទាល់។

រដូវអប់រំពិសេស ជាពេលវេលាពិសេសដើម្បីកសាងសុខសន្តិភាព ដើម្បីកសាងសេចក្តីសុខសាន្តដ៏ពិតប្រាកដនៅក្នុងជីវិតរបស់យើងផ្ទាល់។ ដោយសង្ឃឹមថា នៅពេលយើងមានសេចក្តីសុខ យើងចែករំលែកសេចក្តីសុខនេះដល់បងប្អូនឯទៀតៗ ឱ្យយើងណែនាំបងប្អូនទាំងអស់អាចរួមរស់នៅក្នុងសុខដុមរមនាដែលចេះយល់ចិត្តគ្នា។ ដោយសារ ប្រភពនៃសង្គ្រាម ប្រភពនៃការជំទាស់ គឺការមិនយល់ចិត្តគ្នា មានការច្រណែន ចិត្តលោភលន់។ **តើយើងច្រណែនគេដោយសារគេជាមនុស្សសុចរិតឬយ៉ាងណា? តើយើងច្រណែនគេដោយសារគេធ្វើអំពើល្អមែនទេ? តើយើងច្រណែនគេដោយសារគេចេះស្រឡាញ់បងប្អូនឯទៀតៗឬ?** យើងចេះតែច្រណែនអំពីទ្រព្យសម្បត្តិរបស់គេ ច្រណែនអំពីអ្វីដែលគេមាននៅក្នុងលោកិយ៍។ នៅពេលគេពោរពេញដោយសេចក្តីស្រឡាញ់ ពោរពេញដោយអំពើល្អនៅក្នុងដួងចិត្ត យើងមិនត្រូវការច្រណែនគេទេ។ ឱ្យយើងទៅជាមនុស្សសុចរិតដូចលោកយ៉ៅប ដូចគាត់ដែលបានធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ ដូចគាត់យើងចេះស្រឡាញ់គ្នាទៅវិញទៅមក។ ឱ្យយើងមានចិត្តលោភលន់តាមរបៀបសន្តប៉ូល គាត់គ្មានចិត្តលោភលន់តាមលោកិយ៍ ប៉ុន្តែគាត់មានចិត្តលោភលន់ដើម្បីឱ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ កើតជារូបរាងនៅលើផែនដីសព្វថ្ងៃ។ ចិត្តលោភលន់ ដើម្បីឱ្យព្រះសហគមន៍រីកចម្រើននៅក្នុងសេចក្តីស្រឡាញ់ ដោយរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នេះមានប្រយោជន៍មែនទែនសម្រាប់ជីវិតរបស់យើងនៅលើផែនដីនេះ សម្រាប់ជីវិតរបស់បងប្អូនកូនចៅយើង និងសម្រាប់ជីវិតរបស់យើងនៅស្ថានបរមសុខ។

បងប្អូនជាទីស្រឡាញ់ យើងអធិដ្ឋានតាមរយៈលោកយ៉ៅប តាមរយៈព្រះនាងម៉ារីនៃទន្លេមេគង្គ ដើម្បីឱ្យជីវិតរបស់យើងទៅជាជីវិតថ្មីនៅក្នុងរដូវ៤០ថ្ងៃនេះ ដើម្បីឱ្យយើងរួមរស់តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឱ្យយើងទៅជាមនុស្សសុចរិត។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ឆ្មឹតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/cOpTpGIh7Hw